# ក្រដាសព័ត៌មានៈ  បណ្ណបើកបរ  AB 60

*ចាប់ផ្តើមក្នុង ខែមករា ថ្ងៃទី១ ឆ្នាំ២០១៥ តទៅ ចំពោះប្រជាពលរដ្ឋរស់នៅក្នុងរដ្ឋកាលីហ្វូនីញ៉ា អាចមានសិទ្ធិទទួលប័ណ្ណបើកបរ ដោយគ្មានគិតអំពីអត្តសញ្ញាណអន្តោប្រវេសរបៀបណាឡើយ ។ ចំពោះអ្នកដាក់ពាក្យសុំ ពុំមានអ្វីសម្រាប់បង្ហាញភស្តុតាងអំពីការរស់នៅស្របច្បាប់នោះ ក៏អាចទទួលនូវប័ណ្ណបើកបរ AB 60 នេះ ផងដែរ ហើយប័ណ្ណនេះមានរូបរាងឃើញថា ល្អពិសេសមួយ ។*

## តើខ្ញុំអាចដាក់ពាក្យសុំប័ណ្ណនេះ ដោយរបៀបណា?

ក្រសួងបើកបរ ឌីអិមវី  DMV តម្រូវអោយប្រជាពលរដ្ឋទាំងអស់ ដែលដាក់ពាក្យសុំប័ណ្ណបើកបរនេះ ធ្វើតាមវិធីទាំងអស់ ដើម្បីអោយប្រាកដថា ពួកគេទាំងអស់គ្នាចេះដឹងអំពីច្បាប់លើផ្លូវ និងចេះបើកបរមានសុវត្ថភាព ។ ដើម្បីដាក់ពាក្យសុំប័ណ្ណបើកបរ  AB 60 នេះ អ្នកត្រូវតែធ្វើតាមអ្វីៗ ដែលបង្ហាញប្រាប់ដូចខាងក្រោមនេះ :

១.  ដាក់ថ្ងៃណាត់ជួប សម្រាប់សុំដាក់ពាក្យនៅឯ ក្រសួងបើកបរឌីអិមវី  DMV  ។ អ្នកអាចដាក់ពាក្យសុំប័ណ្ណបើកបរនេះ  តែមួយគត់ នៅកន្លែង  DMV  ។ ផងដែរ សូមមេត្តាបង់ថ្លៃសំបុត្រផាកពិន័យចរាចរណ៍ ដែលធ្លាប់មានពីមុនៗ អោយបានជ្រះស្រឡះសិន មុននឹងដាក់ពាក្យសុំប័ណ្ណបើកបរនេះ ។

២.  បំពេញក្រដាសដាក់ពាក្យ ប័ណ្ណ DL-44  ។ បើសិនរូបអ្នក ទទួលបានស្របច្បាប់នូវលេខសំគាល់ខ្លួន សូស្យាល់សិកខ្យួរីធី ចេញពីក្រសួង សូស្យាល់សិកខ្យួរីធីនោះ អ្នកគួរតែសរសេរលេខនៅក្នុងក្រដាស់បំពេញពាក្យនេះ ។ បើសិនរូបអ្នកមិនដែលបានទទួលលេខសូស្យាល់សិកខ្យួរីធីនោះទេ អ្នកគួរតែគូសក្នុងប្រអប់លើក្រដាសបំពេញពាក្យ ដើម្បីបញ្ជាក់អំពីរឿងនេះ ។ សូមកុំសរសេរលេខសូស្យាល់សិកខ្យួរីធីក្លែងក្លាយ ឬលេខណាមួយដែលមិនបានផ្តល់អោយដល់រូបអ្នក ចេញពីក្រសួងសូស្យាល់សិកខ្យួរីធីឡើយ ។ បើសិនជា រូបអ្នកមិនមានសញ្ជាត្តិអាមេរិកាំង  សូមកុំបំពេញក្រដាសបោះឆ្នោតអោយសោះ ។

៣.  បង់ថ្លៃក្រដាសដាក់ពាក្យ  $33 ដុល្លារ  ។

៤.  បង្ហាញភស្តុតាងអត្តសញ្ញាណរបស់អ្នក និងទីលំនៅដ្ឋានក្នុងរដ្ឋកាលីហ្វូនីញ៉ា ប្រើប្រាស់រួមបញ្ចូលឯកសារផ្សេងៗ ដែលទទួលស្គាល់ដោយក្រសួងឌីអិមវី ។

៥.  ប្រលងជាប់តែស្តសរសេរ ដើម្បីបញ្ជាក់ថា រូបអ្នកចេះដឹងអំពីច្បាប់ចរាចរណ៍លើផ្លូវ ។

៦.  ផ្តិតមេដៃ

៧.  ថតរូបរបស់អ្នក

៨.  ជាប់តែស្តភ្នែក

៩.  ក្រោយពីបានទទួលលិខិតអនុញ្ញាត អោយអង្គុយបើកបរ ជាមួយអ្នកបើកបរម្នាក់រួចហើយ សូមដាក់ថ្ងៃណាត់ជួបត្រឡប់ទៅ  DMV  វិញ ដើម្បីធ្វើតែស្តប្រលងបើកបរលើផ្លូវ ។

១០.  សូមបង្ហាញភស្តុតាងធានារ៉ាប់រង សម្រាប់រថយន្តរបស់អ្នក

១១.  ក្រោយពីការប្រលងជាប់តែស្តបើកបរលើផ្លូវ ដែលរូបអ្នកបានបង្ហាញពីសម្ថភាពបើកបរដោយសុវត្ថភាពរួចហើយ អ្នកនឹងទទួលបានប័ណ្ណបើកបរ AB60 របស់អ្នក ។



DRIVE CA — IT'S TIME TO DRIVE CALIFORNIA FORWARD

## អត្តសញ្ញាណ  និងឯកសារទីលំនៅដ្ឋាន

លោកអ្នកត្រូវតែមានអត្តសញ្ញាណ និងឯកសារទីលំនៅដ្ឋានក្នុងរដ្ឋកាលីហ្វនីញ៉ា សម្រាប់យកមកបង្ហាញក្រសួងបើកបរ ឌីអិមវី DMV និងប្រើរួមឯកសារផ្សេងៗ។ លិខិតឆ្លងដែនបច្ចុប្បន្នរបស់ជនបរទេស និងកាតអាយឌីពីស្ថានទូតកុងស៊ុល ឬលិខិតឆ្លងដែនជនបរទេស ដែលផុតកំណត់រួចហើយ និងសំបុត្រកំណើតជនបរទេស ( បកប្រែដោយស្ថានទូតកុងស៊ុល) អាចប្រើប្រាស់ជាភស្តុតាង បង្ហាញអត្តសញ្ញាណរបស់អ្នក។  អ្នកត្រូវតែមានទីលំនៅដ្ឋានក្នុងរដ្ឋកាលីហ្វនីញ៉ា ដែលអាចបញ្ជាក់ប្រាប់ជាឯកសាមួយដូចខាងក្រោមនេះ : សំបុត្រជួលផ្ទះ សំបុត្រថ្លៃប្រើប្រាស់ផ្សេងៗ  ក្រដាសពន្ធដារធ្វើតាក់ប្រចាំឆ្នាំ សំណុំឯកសាពេទ្យ សំណុំឯកសារថវិការផ្នែកសិក្សាអប់រំ ឬសំណុំឯកសាផ្នែកសាសាលារៀន។ បើសិន រូបអ្នកមិនមានឯកសារទាំងនោះទេ អ្នកអាចយកឯកសារអ្វីមួយផ្សេងទៀតក៏បានដែរ ហើយខាងបុគ្គលិក DMV  នឹងសម្ភាសន៏ជាមួយរូបអ្នក ដើម្បីមើលអោយច្បាស់ថា ឯកសាររបស់អ្នកពិតប្រាកដត្រឹមត្រូវស្របច្បាប់ និងពិនិត្យមើលអោយដូចគ្នា ជាមួយអត្តសញ្ញាណរបស់អ្នក។

## ប្រលងធ្វើតែស្ត:

អ្នកដាក់ពាក្យសុំទាំងអស់ ត្រូវបង្ហាញការចេះដឹងរបស់គាត់ ឬនាង អំពីច្បាប់បើកបររដ្ឋកាលីហ្វនីញ៉ា និងសម្ថភាពបើកបរមានសុវត្ថភាព។ អ្នកត្រូវតែប្រលងអោយជាប់តែស្តសរសេរ "ច្បាប់ចរាចរលើផ្លូវ " នៅក្នុងថ្ងៃដែលរូបអ្នកបានដាក់ញ្យសុំប័ណ្ណបើកបររបស់អ្នក។ ទាំងនោះ អ្នកអាចធ្វើតែស្តសរសេរ ឬតែស្តនិយាយ ដែលមានក្នុងភាសាផ្សេងៗ។ ក្រោយពីបានទទួលលិខិតអនុញ្ញាតអោយរៀនបើកបររួចហើយ អ្នកត្រូវតែដាក់ថ្ងៃណាត់ត្រឡប់ទៅជួបក្រសួង  DMV វិញ ដើម្បីប្រលងអោយជាប់តែស្តបើកបរនោះ អ្នកត្រូវតែបង្ហាញសម្ថភាពបើកបរមានសុវត្ថភាព។ បន្ទាប់ពីនោះ អ្នកនឹងទទួលបានប័ណ្ណបើកបររបស់អ្នក។

## តើខ្ញុំអាចរៀបចំធ្វើអ្វីខ្លះ  ក្នុងពេលឥឡូវនេះ?

ការសម្រេចចុងក្រោយ លើឯកសារអត្តសញ្ញាណ និងទីលំនៅដ្ឋាន ដែលជាសេចក្តីតម្រូវការទាំងនោះ គឺកំពុងពិនិត្យវិនិឆ្ឆ័យដោយក្រសួង  DMV ។ ទោះជាយ៉ាងណាក៏ដោយ អ្នកអាចចាប់ផ្តើមប្រមូលឯកសាររបស់អ្នកក្នុងពេលឥឡូវនេះ។ បើសិនរូបអ្នក មិនមានកាតអាយឌី ពីស្ថានទូតកុងសូល ឬ លិខិតឆ្លងដែន ក៏ប៉ុន្តែ អាចទៅយកបាននៅស្ថានទូតរបស់អ្នក ហេតុនេះ អ្នកគួរតែចាប់ផ្តើមធ្វើឥឡូវនេះ។ ការិយាល័យស្ថានទូតខ្លះ ប្រើពេលវេលាយូណាស់ក្នុងការធ្វើឯកសារទាំងនោះ។ បើសិនរូបអ្នកមិនមានឯកសារទីលំនៅដ្ឋានក្នុងឈ្មោះរបស់អ្នកទេ អ្នកគួរតែផ្លាស់ប្តូរឈ្មោះថ្លៃប្រើប្រាស់ផ្សេងៗ ឬឯកសារស្រដៀងគ្នានោះ មកជាឈ្មោះរបស់អ្នកវិញ ( សូមចំណាំ ចំពោះអ្នកដាក់ពាក្យ អាចអនុញ្ញាត្តអោយប្រើ ឯកសារមានឈ្មោះរបស់ប្តី ឬប្រពន្ធសម្រាប់បញ្ជាក់ពីទីលំនៅដ្ឋាន ក៏ប៉ុន្តែ មិនអនុញ្ញាត្តដល់ជនណា ដែលមានទីលំនៅដ្ឋានចែកគ្នាស្នាក់នៅ ) ។

បើសិនជារូបអ្នកធ្លាប់បើកបរពីមុន  ហើយ ធ្លាប់បានទទួលសំបុត្រផាកពិន័យចរាចរណ៏ សូមធ្វើអោយប្រាកដថាបានបង់ថ្លៃសំបុត្រនោះរួចហើយ។ បើសិនរូបអ្នកមិនប្រាកដថា រូបអ្នកបង់ថ្លៃពិន័យចរាចណ៏ត្រឹមត្រូវឬអត់ សូមអញ្ជើញទៅក្រសួង DMV ដែលមាននៅជិតអ្នក ជាប្រញ៉ាប់ ដើម្បីសុំសំណុំរឿងបើកបររបស់អ្នក។ សូមកុំភ្លេចថា ត្រូវប្រាប់ឈ្មោះ និងអស័យដ្ឋាន ដែលរូបអ្នកបានអោយទៅភ្នាក់ងារ ក្នុងពេលប្រព្រឹត្តបទល្មើសនោះ។ អ្នកអាចទៅបង់ថ្លៃសំបុត្រពិន័យ នៅទីកន្លែងសាលតុលាការណាមួយ ដែលបានដាក់កំណត់អោយទៅ។ បើសិន រូបអ្នកមានការព្រួយបារម្ភណ៏ អំពីសំណុំរឿងបើកបររបស់អ្នក សូមពិភាក្សាជាមួយមេធាវីស្របច្បាប់។

ការសំខាន់ជាងគេ គឺអ្នកគួរតែចាប់ផ្តើមសិក្សា សម្រាប់ប្រលងធ្វើតែស្ត។ មានព័តិមានផ្សេងៗក្នុង វើបសាយ  www.driveca.org  ក៏មាននៅក្នុងបណ្តាយ DMV និង ភ្នាក់ងារ DMV តាមទីកន្លែងផងដែរ។ សូមកុំបង់ប្រាក់អោយទៅ មនុស្សណាម្នាក់សម្រាប់ប័ណ្ណបើកបរ នៅក្នុងពេលនេះ។ ប័ណ្ណបើកបរនេះ មិនទាន់មានទេ រហូតទៅដល់ខែ មករា ថ្ងៃទី១ ឆ្នាំ២០១៥  និងមានផ្តល់អោយនៅទីកន្លែង  DMV តែមួយគត់។

## តើខ្ញុំអាចចូលរួមមានទំនាក់ទំនង  ដោយរបៀបណា?

*សម្លេងរបស់អ្នកមានសារះសំខាន់ណាស់! ដើម្បីចូលរួម សូមទាក់ទងមកយើង តាមអ៊ីម៉ែល*   driverslicense@caimmigrant.org
*និងចូលរួមជាមួយ អង្គការសហពលផ្នែក បើកបររដ្ឋកាលីហ្វនីញ៉ា ។ ផងដែរ អ្នកអាចយកជាព័តិមានបន្ថែមក្នុងវើបសាយ*   www.driveca.org